**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០១៦

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Aug-2016, 09:08
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ(កោសលុប)

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់ នួន ជា តាមវិធាន ៨៧(៤) សុំឲ្យទទួលយកធ្វើជាភស្តុតាង នូវឯកសាររបស់ ROBERT LEMKIN (2-TCW-877) និងឯកសារពាក់ព័ន្ធដទៃទៀត មុនពេលផ្តល់សក្ខីកម្មរបស់ សាក្សី [redacted] (2-TCW-829)**

---

**ដាក់ដោយ៖**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
Doreen CHEN
ព្រុំ ផល្លា
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI
ឌី សុជាតា

**ផ្ញើជូន៖**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង សហមេធាវីលោក នួន ជា ("មេធាវីការពារក្តី") សូមដាក់សំណើនេះ ("សំណើ") សុំឱ្យទទួលយកធ្វើជាភស្តុតាងនូវប្រតិចារឹកនៃការសម្ភាសន៍របស់សាក្សីបួនរូប ដែលធ្វើឡើងដោយ Robert Lemkin (2-TCW-877) និង ថេត សម្បត្តិ (2-TCW-885) សម្រាប់គោលបំណងនៃការផលិតភាពយន្តរបស់ពួកគេដែលមានចំណងជើងថា "សត្រូវប្រជាជន"[1] ព្រមទាំងកំណត់ត្រាដែលសរសេរដោយ Robert Lemkin (2-TCW-877) ទាក់ទងនឹងការសម្ភាសន៍ទាំងអស់នេះ[2] និងកំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877) ធ្វើឡើងដោយចៅក្រមតំណាងរបស់អង្គជំនុំជម្រះតុលាការកំពូល កាលពីថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៥[3] ព្រមទាំងអត្ថបទដែលចុះផ្សាយក្នុងសារព័ត៌មាន Cambodia Daily Weekend កាលពីថ្ងៃទី១៨ ខែ មិថុនា ឆ្នាំ២០១៦[4]។ មេធាវីការពារក្តីសូមស្នើបន្ថែមឱ្យទទួលយកសម្ភារនេះ មុនពេលសាក្សី [redacted] (2-TCW-829) មកបង្ហាញខ្លួន ដោយសារតែមេធាវីការពារក្តីមានបំណងសួរដេញដោល [redacted] (2-TCW-829) ដោយប្រើប្រាស់ភស្តុតាងដែលបានស្នើសុំទាំងអស់នេះ។

## II. ប្រវត្តិនីតិវិធី

### ក. ភស្តុតាងរបស់ Robert Lemkin

2. នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៤ មេធាវីការពារក្តីបានដាក់សំណើលើកទីមួយរបស់ខ្លួនស្នើសុំឱ្យពិចារណានិងទទួលយកភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខ ដោយបានផ្តោតទៅលើភាពយន្ត

---

[1] ឯកសារ **F2/4/3/3/6.2**, "ប្រតិចារឹកនៃកិច្ចសម្ភាសន៍ដែលផ្តល់ដោយ Robert Lemkin (2-TCW-877)', ថ្ងៃទី២ ខែតុលា ឆ្នាំ ២០១៥ ("ប្រតិចារឹករបស់ Lemkin (2-TCW-877)")។

[2] ឯកសារ **F2/4/3/3.1**, "កំណត់ត្រាដែលមិនបានបោះផ្សាយរបស់ Robert Lemkin (2-TCW-877) អំពីការស៊ើបអង្កេតលើជម្លោះផ្ទៃក្នុងរបស់ខ្មែរក្រហម" ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ("កំណត់ត្រារបស់ Robert Lemkin (2-TCW-877)")។

[3] ឯកសារ **F2/4/3/1**, "កំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877)", ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ("កំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877)").

[4] 'Cambodia Daily Weekend', 18-19 June 2016 (**Attachment 2**), p. 4-7, https://www.cambodiadaily.com/weekend1/factions-or-fiction-114272/

ឯកសារនៃកិច្ចសម្ភាសន៍របស់ Robert Lemkin និង ថេត សម្បត្តិ អំពីសក្ខីកម្មសាក្សី៤រូប[5]។ អង្គជំនុំជម្រះតុលាការកំពូលបានចាប់ផ្តើមការស៊ើបអង្កេតមួយទៅលើភាពយន្តឯកសារ[6]។ ក្នុងពេលស៊ើបសួរនោះ ចៅក្រមតំណាងអង្គជំនុំជម្រះតុលាការកំពូលបានស្តាប់ចម្លើយ Robert Lemkin (2-TCW-877) ដែលបានយល់ព្រមផ្តល់កំណត់ត្រារបស់គាត់ ដែលសង្ខេបពីការសម្ភាសន៍សាក្សីទាំងបួនរូប[7]៖

> អ្វីដែលខ្ញុំអាចធ្វើបាន ហើយដែលខ្ញុំពេញចិត្តនឹងធ្វើគឺ ការផ្តល់ជូនលោកនូវសម្រង់នៃឯកសារ ដែលខ្ញុំបានសរសេរ ហើយដែលនឹងត្រូវដាក់ជាសាធារណៈ ក្នុងពេលឆាប់ៗខាងមុខ ដោយឯកសារនេះនឹងផ្តល់ជាគំនិតជូនលោក អំពីវិសាលភាពនៃអ្វីដែលបុគ្គលទាំងបួននាក់បាននិយាយ ហើយដែលអាចជួយលោក ក្នុងការកំណត់អត្តសញ្ញាណ លើបណ្តាចំណុចទាំងឡាយណាដែលលោកត្រូវការ[8]។

3. នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥ មេធាវីការពារក្តីបានស្នើសុំអង្គជំនុំជម្រះតុលាការកំពូលឱ្យទទួលយកធ្វើជាភស្តុតាងនូវកំណត់ត្រារបស់ Robert Lemkin (2-TCW-877)[9]។

4. នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ Robert Lemkin (2-TCW-877) បានផ្តល់ជូនបន្ថែមដល់អង្គជំនុំជម្រះតុលាការកំពូលនូវប្រតិចារឹកចំនួន ១៨៩ ទំព័រ នៃការសម្ភាសន៍ជាមួយសាក្សីទាំងបួនរូបនោះ ("ប្រតិចារឹករបស់ Robert Lemkin (2-TCW-877)")[10]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ចេញប្រតិចារឹកទាំងអស់នេះជូនទៅភាគីនានា កាលពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៥។ នៅថ្ងៃទី

---

[5] **F2** "សំណើសុំឱ្យទទួល និងពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១" ថ្ងៃទី០១ សីហា ២០១៤។

[6] **F2/4/3** "សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជា សុំឱ្យទទួល និង ពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿង ០០២/០១" ថ្ងៃទី ១ មេសា ២០១៥។ សូមមើលផងដែរ **F2/4/3/3/5** "សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបីស្តីពីការកិច្ចស៊ើបសួរបន្ថែម" ២០ សីហា ២០១៥ ("សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបី")។

[7] ឯកសារ **F2/4/3/3.1**, កំណត់ត្រារបស់ Robert Lemkin (2-TCW-877)។

[8] ឯកសារ **F2/4/3/1**, កំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877), ERN 01097188។

[9] ឯកសារ **F2/4/3/3/1**, "ចម្លើយតបរបស់ នួន ជា ទៅនឹងសំណួរនានាស្តីពី កិច្ចស៊ើបសួរបន្ថែមរបស់ អង្គជំនុំជម្រះតុលាការកំពូល ទៅក្នុងឈុតវីដេអូដែលជាកម្មសិទ្ធិ របស់ផលិតករភាពយន្ត Rob Lemkin (2-TCW-877) និង ថេត សម្បត្តិ (2-TCW-885)', ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៥។

[10] ឯកសារ **F2/4/3/3/6.2**, "ប្រតិចារឹករបស់ Lemkin (2-TCW-877)", ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥។

០៨ ខែតុលា ឆ្នាំ២០១៥ មេធាវីការពារក្តីបានស្នើដល់អង្គជំនុំជម្រះតុលាការកំពូលឱ្យទទួលយកប្រតិចារឹករបស់ Robert Lemkin (2-TCW-877) ធ្វើជាភស្តុតាង[11]។ [redacted] (2-TCW-829)[12] ក្រោយមកត្រូវបានបញ្ជាក់ថាជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលទាំងបួន ដែលត្រូវបានសម្ភាសន៍ និងកត់ត្រាជាប្រតិចារឹក ហើយគាត់បានផ្តល់សក្ខីកម្មរួចហើយនៅក្នុងបណ្តឹងសាទុក្ខ [redacted][13]។

5. នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែមលើបណ្តឹងសាទុក្ខ[14] [redacted] ហើយបានច្រានចោលសំណើទាក់ទងនឹងប្រតិចារឹកនៃកិច្ចសម្ភាសន៍ [redacted] រួមទាំងកំណត់ត្រារបស់ Robert Lemkin (2-TCW-877)។ អង្គជំនុំជម្រះតុលាការកំពូលក៏បានបដិសេធសំណើរបស់មេធាវីការពារក្តីសុំស្តាប់ចម្លើយ Robert Lemkin (2-TCW-877) ឬថេត សម្បត្តិ (2-TCW-885) ក្នុងបណ្តឹងសាទុក្ខ[15]។ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦ មេធាវីការពារក្តីបានស្នើ

---

[11] ឯកសារ **F2/4/3/3/6/1**, "សារណារបស់ នួន ជា អំពីប្រតិចារឹករបស់ Robert LEMKIN (2-TCW-877) និងសារសំខាន់នៃជម្លោះនៅក្នុង ប.ក.ក", ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៥ ("សារណាស្តីពីប្រតិចារឹករបស់ Lemkin និងជម្លោះនៅក្នុង ប.ក.ក")។

[12] ឯកសារ**F2/4/3/3/5**, សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបី ស្តីពីកិច្ចស៊ើបសួរបន្ថែម, ERN 01132012, ជើងទំព័រ ១៥៖ "អ៊ីម៉ែលជាអេឡិចត្រូនិកផ្ញើរពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ("WESU") មកកាន់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូល ដែលមានចំណងជើងថា "បញ្ជូនត៖ បច្ចុប្បន្នភាពស្តីពីកំណត់ហេតុសម្ងាត់" ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥ នៅម៉ោង ០១ និង៥២ ល្ងាច នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ("អ៊ីម៉ែលថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥") (ការបញ្ជូនអ៊ីម៉ែលថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៥ ពីលោក Robert Lemkin ដែលក្នុងអ៊ីម៉ែលគាត់បានសង្កេតថា បុគ្គលដែលបាននិយាយសំដៅថាជា "W2" នៅក្នុងកំណត់ហេតុ បានមកផ្តល់ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ខណៈបុគ្គលដែលបានបង្ហាញអត្តសញ្ញាណជា "WI" និង "W3" នៅក្នុងកំណត់ហេតុ ត្រូវបានបង្ហាញឈ្មោះនៅក្នុងសៀវភៅដែលមានចំណងជើងថា *នៅពីក្រោយវាលពិឃាត*)។ សូមមើលផងដែរ, **F2/9** "សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម លើបណ្តឹងសាទុក្ខ និងបញ្ហាពាក់ព័ន្ធ– ផ្នែកសម្រេចសេចក្តី", ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ("ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះតុលាការកំពូល"), ទំព័រ ៧។

[13] [redacted]។

[14] ឯកសារ **F2/9**, "សេចក្តីសម្រេចលើសំណើសុំដាក់ភស្តុតាងបន្ថែម លើបណ្តឹងសាទុក្ខ និងបញ្ហាពាក់ព័ន្ធ", ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ("ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីសំណើសុំភស្តុតាងរបស់មេធាវីការពារក្តី")។

[15] ឯកសារ **F2/9**, ផ្នែកសម្រេចសេចក្តីរបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីសំណើសុំភស្តុតាងរបស់មេធាវីការពារក្តី, ទំព័រ ៧។

ដល់អង្គជំនុំជម្រះតុលាការកំពូលឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចរបស់ខ្លួនទាក់ទងនឹងការបង្ហាញខ្លួនរបស់ Robert Lemkin (2-TCW-877) និងការទទួលយកកំណត់ត្រា និងប្រតិចារឹករបស់គាត់[16]។ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦ អង្គជំនុំជម្រះតុលាការកំពូលបានបដិសេធសំណើនោះ[17]។

6. នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានស្នើដល់អង្គជំនុំជម្រះតុលាការកំពូលឱ្យផ្ដល់សិទ្ធិចូលពិនិត្យមើលកំណត់ត្រា និងប្រតិចារឹករបស់ Robert Lemkin (2-TCW-877)។ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ មេធាវីការពារក្ដីបានសាកសួរអំពីស្ថានភាពនៃសំណើនេះ។ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះតុលាការកំពូលបានជូនដំណឹងដល់មេធាវីការពារក្ដីថា ខ្លួនរង់ចាំការអនុញ្ញាតពី Robert Lemkin (2-TCW-877) ដើម្បីដាក់បង្ហាញព័ត៌មានបន្ថែមទៀត ហើយអង្គភាពគាំពារសាក្សី និងអ្នកជំនាញទើបតែបានផ្ញើលិខិតទៅគាត់ក្នុងពេលថ្មីៗនេះប៉ុណ្ណោះ។ នៅថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ ក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូលបានចេញអនុស្សរណៈអន្តរការិយាល័យមួយ ដែលជូនដំណឹងដល់ភាគីថា ខ្លួនបានផ្ដល់សិទ្ធិចូលពិនិត្យមើលភស្តុតាងរបស់ Robert Lemkin (2-TCW-877) ជូនដល់អង្គជំនុំជម្រះសាលាដំបូងហើយ[18]។

7. នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦ សារព័ត៌មាន Cambodia Daily បានចេញលេខពិសេសចុងសប្ដាហ៍ មួយដែលរួមមានអត្ថបទចំនួនបួនទំព័ររៀបរាប់ពីសំណុំរឿងលោក នួន ជា ហើយជាពិសេស បានចងក្រងកិច្ចសម្ភាសន៍ និងសម្រង់នៃឯកសារស្រាវជ្រាវទាក់ទងនឹងអត្ថិភាពនៃផែនការផ្ដាច់ខ្លួន ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា និងអនុវត្តដោយឯករាជ្យពីមជ្ឈិមបក្សក្នុងអំឡុងរបប

---

[16] ឯកសារ **F2/10**, "សំណើរបស់នួន ជា សុំឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងការមិនកោះហៅសាក្សី ហេង សំរិន និង Robert Lemkin និងសូមឱ្យទទួលយកភស្តុតាងរបស់ Robert Lemkin នៅក្នុងដំណើរការបណ្ដឹងសាទុក្ខ", ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ("សំណើសុំឱ្យពិចារណាឡើងវិញលើ ហេង សំរិន និង Robert Lemkin")។

[17] ឯកសារ **F2/10/3**, "សេចក្ដីសម្រេចលើសំណើរបស់នួន ជា សុំឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេច ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៥ ស្ដីពីសំណើសុំភស្តុតាងបន្ថែម", ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៦។

[18] ឯកសារ **E375/2/1**, "អនុស្សរណៈអន្តរការិយាល័យ", ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦។

កម្ពុជាប្រជាធិបតេយ្យ[19]។

## ខ. សាក្សីសម្រាប់ "ការបោសសម្អាតផ្ទៃក្នុង"

8. នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីដំបូងអំពីបុគ្គលដប់នាក់ ដែលគ្រោងនឹងមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះក្នុងនាមជា សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញ ពាក់ព័ន្ធនឹងវគ្គសវនាការ "ការបោសសម្អាតផ្ទៃក្នុង" ដែលក្នុងនោះរួមមាន សាក្សី [redacted] (2-TCW-829) ផងដែរ[20]។ នៅថ្ងៃដដែលនោះ មេធាវីការពារក្តីបានដាក់សំណើសុំឱ្យពន្លឿនដំណើរការបង្ហាញខ្លួនរបស់ Robert Lemkin (2-TCW-877) [redacted] (2-TCW-959)[21] និង [redacted] (2-TCW-961)[22] ក្នុងវគ្គសវនាការស្តីពី មន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង"[23]។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានស្នើដល់មេធាវីការពារក្តីឱ្យធ្វើសារណាទាក់ទងនឹងសំណើសុំសាក្សីនេះ ដោយពន្យល់ "ថាតើការវាយតម្លៃទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា មានផលប៉ះពាល់របៀបណា ជាមួយភស្តុតាងបន្ថែម ដែលមានទំនោរទៅរក ការបង្ហាញពីអត្ថិភាពនៃផ្នែកជម្លោះ ឬការប៉ះបោរ បើទោះបីជាមាន ឬមិនមានការគាំទ្រពីប្រទេសដទៃក៏ដោយ?"[24]។ មេធាវីការពារក្តីបានដាក់សារណារបស់ខ្លួននៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦។ អង្គជំនុំជម្រះសាលាដំបូងមិនទាន់សម្រេចទៅលើសំណើសុំសាក្សីនេះនៅ

---

[19] 'Cambodia Daily Weekend', ថ្ងៃទី១៨-១៩ ខែមិថុនា ឆ្នាំ២០១៦(ឧបសម្ព័ន្ធ), ទំព័រ ៤ ដល់៧, https://www.cambodiadaily.com/weekend1/factions-or-fiction-114272/។

[20] ឯកសារ **E395/2.1.3**, សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើរជូនភាគី, ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦។

[21] ដោយត្រូវបានកំណត់អត្តសញ្ញាណជា W3 នៅក្នុងឯកសារ **F2/4/3/3/6.2**, "ប្រតិចារឹករបស់ Lemkin (2-TCW-877)", សូមមើល ឯកសារ **F2/4/3/3/5**, សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបី ស្តីពីកិច្ចស៊ើបសួរបន្ថែម, ERN 01132011, ជើងទំព័រ ១៥ និង ឯកសារ **F2/4/3/3/6/1**, "សារណាស្តីពីប្រតិចារឹករបស់ Lemkin និងជម្លោះនៅក្នុង ប.ក.ក", កថាខណ្ឌ ៨។

[22] ដោយត្រូវបានកំណត់អត្តសញ្ញាណជា W1 in **F2/4/3/3/6.2**, "ប្រតិចារឹករបស់ Lemkin (2-TCW-877)", សូមមើលឯកសារ **F2/4/3/3/5**, សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបី ស្តីពីកិច្ចស៊ើបសួរបន្ថែម, ERN 01132011, ជើងទំព័រ ១៥ និងឯកសារ **F2/4/3/3/6/1**, "សារណាស្តីពីប្រតិចារឹករបស់ Lemkin និងជម្លោះនៅក្នុង ប.ក.ក", កថាខណ្ឌ ៨។

[23] ឯកសារ **E395**, "សំណើលើកទីបីរបស់ នួន ជា សុំកោះហៅសាក្សីសម្រាប់ផ្នែកសវនាការ មន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" សំណុំរឿង ០០២/០២ (ភស្តុតាងនៃការបះបោរក្បត់)", ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦។

[24] ឯកសារ **E395/1**, "សំណើសុំសារណាសង្ខេប ស្តីអំពីសារសំខាន់នៃក្រុមជម្លោះ នៅក្នុងថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ", ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៦។

ឡើយទេ។

## III. ច្បាប់ជាធរមាន

9. រាល់ភស្តុតាងទាំងអស់ត្រូវបានទទួលយក លើកលែងតែមានចែងនៅក្នុងវិធានផ្ទៃក្នុង[25]។ អង្គជំនុំជម្រះអាចបដិសេធសំណើទទួលយកភស្តុតាងក្នុងករណីដែលខ្លួនយល់ឃើញថា ភស្តុតាងមិនមានភាពពាក់ព័ន្ធ ឬក៏ច្រំដែល មិនអាចរកបានក្នុងពេលវេលាសមស្រប មិនអាចបង្ហាញទៅលើអង្គហេតុដែលខ្លួនអាចបង្ហាញ មិនអនុញ្ញាតដោយច្បាប់ ឬក៏នាំឲ្យពន្យារពេលដំណើរការ ឬក៏មិនមានប្រយោជន៍[26]។ ដើម្បីបំពេញលក្ខខណ្ឌនៃវិធាន ៨៧ ដែភស្តុតាង (៣)លត្រូវបានស្នើត្រូវការតែមានភាពពាក់ព័ន្ធ និងអាចជឿជាក់បានតាម*ការពិនិត្យបឋម*[27]។ដោយអនុលោមតាមវិធាន ៨៧ (៤) នៅក្នុងដំណាក់កាលណាក៏ដោយនៅក្នុងអំឡុងពេលសវនាការ ភាគីអាចស្នើសុំឲ្យអង្គជំនុំជម្រះ "ទទួលយកភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត" ដែលជាកម្មវត្ថុនៃភាពតម្រូវនៃវិធាន៨៧(៣)[28]។ ខណៈដែលវិធាន ៨៧(៤) ចែងថា ភស្តុតាងដែលត្រូវបានស្នើត្រូវតែមិនអាចរកបាននៅក្នុងនៅមុនពេលបើកសវនាការ អង្គជំនុំជម្រះនេះបកស្រាយថា វាជាភស្តុតាងដែលអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការ ប៉ុន្តែមិនអាចរកឃើញដោយមានការយកចិត្តទុកដាក់សមស្របនឹងអាចទទួលយក[29]។

10. នៅក្នុងស្ថានភាពជាក់ស្តែងភស្តុតាងដែលមិន "លើកឡើងដោយតឹងរ៉ឹង" បំពេញបានលក្ខខណ្ឌ

---

[25] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[26] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[27] ឯកសារ E289/2 "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E289) និងចម្លើតតបរបស់ខៀវសំផន (ឯកសារ E289/1 )" ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦ ("សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)")។

[28] រយៈពេលមួយឆ្នាំនៅក្នុងសវនាការសំណុំរឿង០២/០២ អង្គជំនុំជម្រះសម្រេចថា ភាគីត្រូវតែដាក់សំណើតាមវិធាន ៨៧(៤) ចំពោះឯកសារដែលមាននៅក្នុងសំណុំរឿង ដែលមិនបានដាក់ចូលក្នុងបញ្ជីដែលអង្គជំនុំជម្រះបានទទួលស្គាល់ បើទោះជាឯកសារទាំងអស់នោះត្រូវបានបង្ហាញដោយសហព្រះរាជអាជ្ញាដែលនាំឲ្យមានការស្នើឡើង។ សូមមើលប្រតិចារិកថ្ងៃទី២៦ ខែ មករា ឆ្នាំ ២០១៦ ទំព័រ ២៤។

[29] ឯកសារ E313 "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៥។ ឯកសារ E289/2 "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

នេះត្រូវបានទទួលយក៖ គឺនៅពេលដែលភស្តុតាងមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅឯកសារដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះ និងនៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានប្រភពដើម្បីវាយតម្លៃ, នៅពេលដែលភស្តុតាងដែលលើកឡើងជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃ ដើម្បីកុំឱ្យប៉ះពាល់ដល់យុត្តិធម៌, ឬក៏នៅពេលដែលភាគីផ្សេងទៀតមិនបានបដិសេធនឹងភស្តុតាង[30]។

11. នៅក្នុងសារអេឡិចត្រូនិចកាលពីថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ទៅភាគីថា:

> *[សំណើជាផ្លូវការអនុលោមតាមវិធាន ៨៧(៤) របស់ភាគី] ត្រូវតែបង្ហាញឯកសារជាក់លាក់ និងថាការស្នើសុំឱ្យទទួលយកជាភស្តុតាងត្រូវធ្វើឡើង ចំពោះចម្លើយកាលពីលើកមុនរបស់បុគ្គលដែលនឹងផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២។ មិនចាំបាច់បង្ហាញហេតុផលនោះទេ[31] ។*

## IV. ឧទ្ធរណ៍

### ក. ឯកសារដែលបានស្នើសុំឱ្យទទួលយក មានភាពពាក់ព័ន្ធ និងអាចជឿជាក់បាន *ជាបឋម*

12. ភស្តុតាងដែលបានស្នើឡើងរួមមាន ប្រតិចារឹកនៃការសម្ភាសន៍ដែលថតដោយ Robert Lemkin (2-TCW-877) និងថេត សម្បត្តិ (2-TCW-885) សម្រាប់ការផលិតខ្សែភាពយន្តរបស់ពួកគេគឺ "សត្រូវប្រជាជន"[32] កំណត់ត្រារបស់ Robert Lemkin (2-TCW-877)[33] និងកំណត់ហេតុស្ដាប់ចម្លើយ Robert Lemkin (2-TCW-877)[34] និងអត្ថបទរបស់ខេមបូឌា ដេលី ដែលបានចេញផ្សាយនៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ២០១៦[35]។ សម្ភារៈទាំងអស់ទាក់ទងជាសំខាន់ជាមួយនឹងហេតុការណ៍

---

[30] សូមមើល ឯកសារ **E289/2** "សេចក្ដីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

[31] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់អង្គជំនុំជម្រះសាលាដំបូងជូនភាគី ថ្ងៃទី២ ខែ មិថុនា ឆ្នាំ២០១៦ (ឯកសារភ្ជាប់ ១)។

[32] ឯកសារ **F2/4/3/3/6.2**, ប្រតិចារឹករបស់ Lemkin (2-TCW-877), ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៥, សូមមើលផងដែរឯកសារ **E186.1R**, "សត្រូវប្រជាជន", Robert Lemkin (2-TCW-877) និង ថេត សម្បត្តិ, ឆ្នាំ ២០០៩។

[33] ឯកសារ **F2/4/3/3.1**, កំណត់ត្រារបស់ Robert Lemkin (2-TCW-877)។

[34] ឯកសារ**F2/4/3/1**, កំណត់ហេតុស្ដាប់ចម្លើយ Robert Lemkin (2-TCW-877)។

[35] 'Cambodia Daily Weekend', 18-19 Jun 2016 (**Attachment 2**), https://www.cambodiadaily.com/weekend1/factions-or-fiction-114272/។

ប៉ះបោរដែលកើតឡើងនៅក្នុងភូមិភាគពាយ័ព្យក្នុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយជាលទ្ធផលពាក់ព័ន្ធជាមួយនឹងការសួរដេញដោលទៅលើសាក្សី [redacted] (2-TCW-829)។

*(១) ប្រតិចារឹករបស់ Robert Lemkin (2-TCW-877)*

13. មេធាវីការពារក្ដីលើកឡើងថា ប្រតិចារឹករបស់ Robert Lemkin (2-TCW-877) គួរត្រូវបានទទួលយកធ្វើជាភស្តុតាងទាំងអស់តែម្ដង ដោយសារតែប្រតិចារឹកនេះមានភស្តុតាងដោះបន្ទុកសំខាន់ដែលពាក់ព័ន្ធខ្លាំងជាមួយនឹងសំណុំរឿង នួន ជា។ លើសពីនេះទៀត តម្លៃនៃភស្តុតាងរបស់ប្រតិចារឹកទាំងនេះមានកម្រិតខ្ពស់។ តាមពិតទៅ ប្រតិចារឹកទាំងនេះគឺជាព័ត៌មានជាលាយលក្ខណ៍អក្សរនៃកិច្ចសម្ភាសន៍ជាច្រើនរបស់គាត់ជាមួយនឹងសាក្សីសំខាន់ៗចំនួនបួននាក់ (W1, W2, W3, និង W4) ដែលបីនាក់ក្នុងចំណោមពួកគេ ត្រូវបានស្នើសុំឱ្យធ្វើជាសាក្សីរបស់មេធាវីការពារក្ដី។ តាមពិតទៅ ដូចបានបញ្ជាក់ពីខាងលើ Robert Lemkin បានបញ្ជាក់ថា បុគ្គលដែលបានកំណត់ថាជា W4 នៅក្នុងប្រតិចារឹករបស់គាត់គឺ [redacted] (2-TCW-829)[36]។ Robert Lemkin (2-TCW-877) បញ្ជាក់បន្ថែមដល់អង្គភាពគាំពារសាក្សី និងអ្នកជំនាញថា បុគ្គលដែលត្រូវបានកំណត់ថាជា "W1" និង "W3" នៅក្នុងកំណត់ត្រា មានឈ្មោះនៅក្នុងសៀវភៅដែលមានចំណងជើងថា "នៅពីក្រោយវាលពិឃាត"[37]។ ដោយផ្អែកលើការពិនិត្យប្រតិចារឹករបស់ Robert Lemkin (2-TCW-877) និងកំណត់ត្រារបស់ Robert Lemkin (2-TCW-877) មេធាវីការពារក្ដីសូមលើកឡើងថា W1 និង W3 គឺជាសាក្សីពីរនាក់ក្នុងចំណោមសាក្សី ដែលមេធាវីការពារក្ដីបានស្នើឱ្យមកបង្ហាញខ្លួន នៅក្នុងបញ្ជីសាក្សី និងអ្នកជំនាញថ្មី សម្រាប់សំណុំរឿង ០០២/០២[38] ("បញ្ជីសាក្សីថ្មី") ដែលជា 2-TCW-961 និង 2-TCW-959[39]។ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦ មេធាវីការពារក្ដីបានស្នើថា ការមកបង្ហាញខ្លួនរបស់សាក្សីទាំងអស់នេះ គួរត្រូវបានពន្លឿននៅក្នុងវគ្គសវនាការស្ដីពីមន្ទីរ

---

[36] ឯកសារ **F2/4/3/3/5**, សេចក្ដីសម្រេចបណ្ដោះអាសន្នលើកទីបី ស្ដីពីកិច្ចស៊ើបសួរបន្ថែម, ERN 01132012, ជើងទំព័រ ១៥។

[37] ឯកសារ **F2/4/3/3/5**, សេចក្ដីសម្រេចបណ្ដោះអាសន្នលើកទីបី ស្ដីពីកិច្ចស៊ើបសួរបន្ថែម, ERN 01132011, ជើងទំព័រ ១៥។

[38] ឯកសារ **E307/4**, "បញ្ជីឈ្មោះសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មី សម្រាប់សំណុំរឿង ០០២/០២" ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤។

[39] ឯកសារ **E307/4.3**, "ឧបសម្ព័ន្ធ ខ – សេចក្ដីសង្ខេបសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញថ្មី សម្រាប់សំណុំរឿង ០០២/០២", ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៤("សេចក្ដីសង្ខេបសាក្សីថ្មី"), ទំព័រ ១ ដល់២។

សន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ក្នុងសំណុំរឿង ០០២/០២[40]។ អង្គជំនុំជម្រះសាលាដំបូង មិនទាន់បានចេញសេចក្តីសម្រេចទាក់ទងនឹងសំណើសុំសាក្សីទាំងអស់នេះនៅឡើយទេ។

14. **ភាពពាក់ព័ន្ធនៃប្រតិចារឹកការសម្ភាសន៍ [redacted] (2-TCW-829) ដោយ Robert Lemkin៖** ដូចដែលបានបញ្ជាក់ពីខាងលើ បុគ្គលដែលត្រូវបានកំណត់ថាជា W2 នៅក្នុងប្រតិចារឹករបស់ Robert Lemkin តាមពិតទៅ គឺ [redacted] (2-TCW-829)[41] ជាសាក្សី [redacted] ដែលបានមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល [redacted][42]។ អនុលោមតាមការបញ្ជាក់ចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការប្រើប្រាស់សំណើតាមវិធាន ៨៧(៤) នៃ វិធានផ្ទៃក្នុង ប្រតិចារឹកការសម្ភាសន៍ [redacted] (2-TCW-829) ដោយ Robert Lemkin គួរត្រូវបានទទួលយកធ្វើជាភស្តុតាង ជាកំណត់ហេតុស្តាប់ចម្លើយកន្លងមករបស់សាក្សីដែលត្រូវមកបង្ហាញខ្លួន[43]។ លើសពីនេះទៀត មេធាវីការពារក្តីសូមបញ្ជាក់ថា ខ្លួនបានសង្កេតឃើញពីភាពមិនស៊ីសង្វាក់គ្នាខ្លាំងរវាងការសម្ភាសន៍ [redacted] (2-TCW-829) ដោយ Robert Lemkin (2-TCW-877) កំណត់ហេតុស្តាប់ចម្លើយចំនួនពីររបស់គាត់[44] និងសក្ខីកម្មផ្ទាល់របស់គាត់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល លើបញ្ហាជាគន្លឹះផ្សេងៗ។ ហេតុដូច្នេះ ការទទួលយកប្រតិចារឹកទាំងនេះធ្វើជាភស្តុតាង រឹតតែមានសារៈសំខាន់សម្រាប់ការសួរដេញដោលនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ ភាពមិនស៊ីសង្វាក់គ្នាទាំងនេះរួមមាន៖

[redacted]

---

[40] ឯកសារ **E395**, "សំណើលើកទីបីរបស់ នួន ជា សុំកោះហៅសាក្សីសម្រាប់ផ្នែកសវនាការ មន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" សំណុំរឿង ០០២/០២ (ភស្តុតាងនៃការបះបោរក្បត់)", ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦។

[41] ឯកសារ **F2/4/3/3/6/1**, "សារណាស្តីពីប្រតិចារឹករបស់ Lemkin និងជម្លោះនៅក្នុង ប.ក.ក", កថាខណ្ឌ ១០។

[42] សូមមើល, [redacted]។

[43] សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះសាលាដំបូង ផ្ញើរជូនភាគី, ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៦ (ឧបសម្ព័ន្ធ ១)។

[44] ឯកសារ **E319.1.27**, "កំណត់ហេតុស្តាប់ចម្លើយ [redacted] [2-TCW-829]', 10 Sep 2013 ("កំណត់ហេតុស្តាប់ចម្លើយលើកទីមួយ របស់ [redacted] [2-TCW-829]")។ ឯកសារ **E319.1.28**, "កំណត់ហេតុស្តាប់ចម្លើយ [redacted] [2-TCW-829]', ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣។

[redacted]

[redacted]

[redacted]

45 [redacted]។

46 **F2/4/3/3/6.2**, ប្រតិចារឹក Lemkin ERN 01151761 [redacted]។

47 **F2/4/3/3/6.2**, ប្រតិចារឹក Lemkin ERN 01151766-67 [redacted]

48 ទាក់ទងនឹង Hay Sau សូមមើល F2/8, សំណើលើកទីប្រាំមួយសុំទទួលយកភស្តុតាងបន្ថែម នៅកថាខណ្ឌ៣១ និង ៦២ និងជើងទំព័រ១០២។

49 [redacted]

50 **F2/4/3/3/6.2**, ប្រតិចារឹក Lemkin ERNs 01151762-63។

51 **F2/4/3/3/6.2**, ប្រតិចារឹក Lemkin ERN 01151764

[redacted]

15. បន្ថែមពីលើនេះ ភាពមិនស្របគ្នាមួយចំនួនតូចក៏លេចចេញឡើង។ [redacted]

---

52 [redacted]។

53 **F2/4/3/3/6.2**, ប្រតិចារឹក Lemkin ERN 01151765។

54 **F2/4/3/3/6.2**, ប្រតិចារឹក Lemkin ERN 01151754 សូមផងដែរ **F2/8** សំណើលើកទីប្រាំមួយសុំភស្តុតាងបន្ថែម កថាខណ្ឌ ៣៣ និង ៣៤។

55 **E319.1.27** កំណត់ហេតុស្តាប់ចម្លើយ [redacted] [2-TCW-829], លើកទីមួយ ERN 00974014-15

56 [redacted]។

57 **F2/4/3/3/6.2**, ប្រតិចារឹក Lemkin ERN 01151754។

58 **F2/4/3/3/6.2**, ប្រតិចារឹក Lemkin ERN 01151755។

[redacted]។

16. ដូចដែលមេធាវីការពារក្តីបានលើកឡើងនៅក្នុងសំណើទីបីរបស់ខ្លួនសុំភស្តុតាងបន្ថែម [redacted] (2-TCW-829) [redacted] ហើយដូច្នេះគាត់គឺជាសាក្សីសំខាន់ទាក់ទងនឹងមិនត្រឹមតែទួលពោធិ៍ជ្រៃ ប៉ុណ្ណឹងទេ តែបញ្ហាធំៗទាក់ទងនឹងរចនាសម្ព័ន្ធ ប.ក.ក និងចំណងទាក់ទងគ្នា រវាងថ្នាក់ដឹកនាំភូមិភាគពាយ័ព្យ និង ប៉ុល ពត និង នួន ជា ផងដែរ។ ម្យ៉ាងទៀត មេធាវីការពារក្តីក៏បានកត់សំគាល់រួចមកហើយនៅក្នុងសំណើលើកទីបីរបស់ខ្លួនសុំភស្តុតាងបន្ថែមថា ចំណុចពិសេសនៃសក្ខីកម្មរបស់ [redacted] (2-TCW-829) បានលេចចេញឡើងនូវការបារម្ភសំខាន់ទាក់ទងនឹងសច្ចៈសីលភាពនៃព្រឹត្តិការណ៍នានាដូចដែលគាត់បានពិពណ៌នា។

17. ការបារម្ភនេះត្រូវបានពង្រឹក និងបង្ហាញដោយប្រតិចារឹក។ ឧទាហរណ៍ប្រតិចារឹកលើកឡើងថា [redacted] (2-TCW-829) អាចដឹងច្រើនទៀតទាក់ទងនឹង [redacted]។

---

[59] **F2/4/3/3/6.2**, ប្រតិចារឹក Lemkin ERN 01151759។ (នៅចំណុចមួយដែល [redacted] (2-TCW-829) បាននិយាយថា [redacted]។

[60] សូមមើលកថាខណ្ឌ ៣៨ ដល់ ៤០ ខាងលើ។ សូមមើលផងដែរ **F2/8** សំណើលើកទីប្រាំមួយសុំភស្តុតាងបន្ថែម នៅកថាខណ្ឌ ៣៤, ៣៨-៤០ និង ៤៣។

[61] សូមមើលកថាខណ្ឌ ៤១ ខាងក្រោម។ សូមមើលផងដែរ **F2/8** សំណើលើកទីប្រាំមួយសុំភស្តុតាងបន្ថែម នៅកថាខណ្ឌ៣១ និង ៦២ និង ជើងទំព័រ១០២។

[62] សូមមើលផងដែរ **F2/8** សំណើលើកទីប្រាំមួយសុំភស្តុតាងបន្ថែម នៅកថាខណ្ឌ៣៤ និង ៣៥ ។

[63] សូមមើលកថាខណ្ឌ ៣៩ ដល់ ៤០ ខាងក្រោម។

18. **ការពាក់ព័ន្ធនៃប្រតិចារឹកនៃកិច្ចសម្ភាសន៍រវាង W1, W2, W3 និង W4 ជាមួយ Robert Lemkin សម្រាប់ការសួរដេញដោល [redacted] (2-TCW-829)៖** សក្ខីកម្មរបស់ [redacted] (2-TCW-829) និងសាក្សីបីនាក់ផ្សេងទៀតដែល Robert Lemkin បានសម្ភាសន៍ មានការទាក់ទងគ្នាទៅវិញទៅមកយ៉ាងជិតខ្លាំង ហើយមេធាវីការពារក្តីមានបំណងសួរដេញដោលសាក្សី [redacted] (2-TCW-829) ដែលគ្រោងនឹងមកបង្ហាញខ្លួន ពាក់ព័ន្ធនឹងប្រតិចារឹកទាំងបួននេះ។ ហេតុដូច្នេះ មេធាវីការពារក្តីសូមលើកឡើងថា ប្រតិចារឹករបស់ Robert Lemkin (2-TCW-877) គួរត្រូវបានទទួលយកទាំងអស់។

[redacted]

[redacted]

---

[64] ឯកសារ **F2/4/3/3/6.2**, ប្រតិចារឹករបស់ Robert Lemkin (2-TCW-877), ERN 01151684, គូសបញ្ជាក់បន្ថែម។

[65] ឯកសារ **F2/4/3/3/6.2**, ប្រតិចារឹករបស់ Robert Lemkin (2-TCW-877), ERN 01151685, គូសបញ្ជាក់បន្ថែម។

[66] **ឯកសារ F2/4/3/3/6.2**, ប្រតិចារឹករបស់ Robert Lemkin (2-TCW-877), ERN 01151689, គូសបញ្ជាក់បន្ថែម.

[redacted]

[redacted]

[67] **ឯកសារ F2/4/3/3/6.2**, ប្រតិចារឹករបស់ Robert Lemkin (2-TCW-877), ERN 01151696, គូសបញ្ជាក់បន្ថែម។

[68] **ឯកសារ F2/4/3/3/6.2**, ប្រតិចារឹករបស់ Robert Lemkin (2-TCW-877), ERN 01151699, គូសបញ្ជាក់បន្ថែម។

[69] **ឯកសារ F2/4/3/3/6.2**, ប្រតិចារឹករបស់ Robert Lemkin (2-TCW-877), ERN 01151705, គូសបញ្ជាក់បន្ថែម។

[70] **ឯកសារ F2/4/3/3/6.2**, ប្រតិចារឹករបស់ Robert Lemkin (2-TCW-877), ERN 01151710, គូសបញ្ជាក់បន្ថែម។

[redacted]។

[redacted]

[redacted]។

21. **ការពាក់ព័ន្ធនៃប្រតិចារឹកកិច្ចសម្ភាសន៍របស់ W1 W3 និង W4 ជាមួយនឹង Robert Lemkin សម្រាប់ការរៀបចំរឿងក្តីរបស់មេធាវីការពារក្តីជាទូទៅ៖** មេធាវីការពារក្តីបានលើកឡើងបន្ថែមថា

[71] **ឯកសារ F2/4/3/3/6.2,** ប្រតិចារឹករបស់ Robert Lemkin (2-TCW-877), ERN 01151710។

[72] [redacted]

[73] **ឯកសារ F2/4/3/3/6.2,** ប្រតិចារឹករបស់ Robert Lemkin (2-TCW-877), ERN 01151814២។

[74] **ឯកសារ F2/4/3/3/6.2,** ប្រតិចារឹករបស់ Robert Lemkin (2-TCW-877), ERN 01151815។

ប្រតិចារឹករបស់ Robert Lemkin គួរត្រូវបានទទួលយកទាំងអស់ [redacted]។ ហេតុដូច្នេះ សក្ខីកម្មទាំងអស់នេះគឺជាចំណុចស្នូលនៃការរៀបចំរឿងក្តីរបស់មេធាវីការពារក្តី ហើយពាក់ព័ន្ធមិនត្រឹមតែជាមួយនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងវគ្គសវនាការទាក់ទងនឹងមន្ទីរសន្តិសុខ និង "ការបោសសម្អាតផ្ទៃក្នុង" ប៉ុណ្ណោះទេ ថែមទាំងជាមួយនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ចំពោះឧក្រិដ្ឋកម្មទាំងអស់ដែលត្រូវបានចោទប្រកាន់ក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ផងដែរ[75]។

[redacted]

[redacted]

[redacted]

---

[75] សូមមើលឯកសារ **E395/2**, "សារណារបស់ នួន ជា ស្តីពីភាពពាក់ព័ន្ធនៃភស្តុតាង របស់ការបះបោរក្បត់ ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គលរបស់គាត់ ក្នុងសំណុំរឿង ០០២/០២", ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៥, កថាខណ្ឌ ១៧ ដល់៤២។

[76] សូមមើលផងដែរ **F2/8** "សំណើលើកទីប្រាំមួយរបស់ នួន ជា" នៅកថាខណ្ឌ៣២។

[77] **F2/4/3/3/6.2** "ប្រតិចារឹកនៃការសម្ភាសន៍ ដែលផ្តល់ដោយ Rob Lemkin ("ប្រតិចារឹក Lemkin") ERN 01151695, [redacted] នៅក្នុង សំណើលើកទីប្រាំមួយសុំទទួលយកភស្តុតាងបន្ថែម មេធាវីការពារក្តីក៏បាននិយាយលម្អិតពីការប្រជុំផ្សេងៗ ដើម្បីរៀបចំ ផែនការបះបោរៈ សូមមើលផងដែរ F2/8។ សំណើលើកទីប្រាំមួយសុំទទួលយកភស្តុតាងបន្ថែម កថាខណ្ឌ ៤០។

[redacted]

[redacted]

[redacted]

[redacted]

23. **ការចាត់ចំណាត់ថ្នាក់ជាឯកសារសាធារណៈ៖** ជាចុងក្រោយ មេធាវីការពារក្តីបានលើកឡើងថា

---

[78] សូមផងដែរ សូមមើលផងដែរ F2/8, សំណើលើកទីប្រាំមួយសុំទទួលយកភស្តុតាងបន្ថែម នៅកថាខណ្ឌ៣៩។

[79] **F2/4/3/3/6.2** ប្រតិចារឹក Lemkin ERN 01151787 សូមផលដែរ F2/8, សំណើលើកទីប្រាំមួយសុំទទួលយកភស្តុតាងបន្ថែម នៅកថាខណ្ឌ៥០។

[80] **F2/4/3/3/6.2** ប្រតិចារឹក Lemkin ERN 01151790

[81] **F2/4/3/3/6.2** ប្រតិចារឹក Lemkin ERN 01151818។

[82] **F2/4/3/3/6.2** ប្រតិចារឹក Lemkin ERN 011511801-26។ សូមមើលផងដែរ F2/8, សំណើលើកទីប្រាំមួយសុំទទួលយក ភស្តុតាងបន្ថែម នៅកថាខណ្ឌ៥០ និង ៥២។ សូមមើលផងដែរ F2/8, សំណើលើកទីប្រាំមួយសុំទទួលយកភស្តុតាងបន្ថែម នៅកថាខណ្ឌ៤២។ (ស្តីពីការប៉ុនប៉ងធ្វើឃាតចំនួនពីរដង) និង កថាខណ្ឌ៤៦ និង ៥០ (ស្តីពី មាន ហៅ ចាន់ ចង្រ្កឹ)។

[83] **F2/4/3/3/6.2** ប្រតិចារឹក Lemkin ERN 01151718-19។

ប្រសិនបើត្រូវបានទទួលយកនោះ ប្រតិចារឹកទាំងនេះគួរត្រូវបានចាត់ចំណាត់ថ្នាក់ជាឯកសារសាធារណៈ។ សាក្សីបីនាក់ក្នុងចំណោមសាក្សីបួននាក់ ត្រូវបានបង្ហាញអត្តសញ្ញាជាសាធារណៈរួចទៅហើយនៅក្នុងសៀវភៅដែលបានបោះពុម្ពផ្សាយរួច គឺ "នៅពីក្រោយវាលពិឃាត" ហើយសាក្សីមួយរូបក្នុងចំណោមសាក្សីទាំងបីនោះ បានមកផ្តល់សក្ខីកម្មជាសាធារណៈនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល។ ហេតុដូច្នេះ ការព្រួយបារម្ភណាមួយទៅលើការការពារត្រង់ចំណុចនេះមិនមានប្រសិទ្ធភាពទេ។ ចំពោះបុគ្គលចុងក្រោយដែលត្រូវបានកំណត់អត្តសញ្ញាណថាជា W4 នៅក្នុងកំណត់ត្រា និងប្រតិចារឹករបស់ Robert Lemkin (2-TCW-877) ហើយមិនទាន់ត្រូវបានបង្ហាញអត្តសញ្ញាណរបស់គាត់ជាសាធារណៈនោះ មេធាវីការពារក្តីសូមលើកឡើងថា បញ្ហាណាមួយនៃការការពារ ទាក់ទងនឹងសាក្សីរូបនេះ អាចត្រូវបានដោះស្រាយតាមរយៈការកោសលុបរាល់ព័ត៌មាននានានៅក្នុងប្រតិចារឹក ដែលអាចកំណត់អត្តសញ្ញាណ W4 ដោយគ្រាន់តែយោងទៅ W4 តាមរយៈរហស្សនាមប៉ុណ្ណោះ។ លើសពីនេះទៀត សារៈសំខាន់ខ្លាំងនៃភស្តុតាងដែលមាននៅក្នុងប្រតិចារឹកទាំងអស់នេះ មិនមែនសម្រាប់តែការរៀបចំរឿងក្តីរបស់មេធាវីការពារក្តីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចជួយដល់ការស្វែងរកការពិតនោះ ធ្វើឲ្យចាំបាច់ត្រូវចាត់ចំណាត់ថ្នាក់ឯកសារទាំងនេះទៅជាឯកសារសាធារណៈ ដើម្បីជាប្រយោជន៍នៃយុត្តិធម៌ ស្របតាមវិធាន ១០៤(១) នៃវិធានផ្ទៃក្នុង។

*(២) កំណត់ត្រារបស់ Robert Lemkin (2-TCW-877)*

24. កំណត់ត្រារបស់ Robert Lemkin (2-TCW-877) សង្ខេបតាមប្រធានបទ នូវកិច្ចសម្ភាសន៍របស់គាត់ជាមួយនឹងសាក្សីទាំងបួននាក់ ដែលបានចូលរួមក្នុងការបះបោរនៅភូមិភាគពាយ័ព្យ ព្រមទាំងបញ្ចូលព័ត៌មានដែលមិនមាននៅក្នុងប្រតិចារឹក[84] ហើយប្រហែលជាគាត់បានទទួលពីប្រភពផ្សេងៗមក ដូចជា ការសម្ភាសន៍ជាមួយបុគ្គលផ្សេង ដោយសារតែគាត់បានបញ្ជាក់ថា គាត់បានសម្ភាសន៍មនុស្សជាច្រើនសម្រាប់ការផលិតភាពយន្តរបស់គាត់[85]។ មេធាវីការពារក្តីក៏មានបំណងសួរដេញដោល [redacted] (2-TCW-829) ដោយប្រើកំណត់ត្រារបស់ Robert Lemkin (2-TCW-877)

---

[84] សូមមើល ជាឧទាហរណ៍ ឯកសារ **F2/4/3/3.1**, កំណត់ត្រារបស់ Robert Lemkin (2-TCW-877), ERN 01106928, [redacted] ព័ត៌មានដែលមាននៅក្នុងផ្នែកនេះ មិនមែនជាផ្នែកនៃប្រតិចារឹក ដែល Robert Lemkin (2-TCW-877) ផ្តល់ជូនទៅអង្គជំនុំជម្រះតុលាការកំពូលឡើយ។

[85] ឯកសារ **F2/4/3/1**, កំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877), ERN 01097184។

ផងដែរ។ ហេតុដូច្នេះ មេធាវីការពារក្តីសូមលើកឡើងថា កំណត់ត្រារបស់ Robert Lemkin (2-TCW-877) ជួយបំពេញបន្ថែមដល់ប្រតិចារឹក ហើយគួរត្រូវបានទទួលយកធ្វើជាភស្តុតាង។

25. **ការចាត់ចំណាត់ថ្នាក់ជាឯកសារសាធារណៈ៖** សម្រាប់មូលហេតុដូចបានបញ្ជាក់ពីខាងលើ មេធាវីការពារក្តីសូមលើកឡើងបន្ថែមថា កំណត់ត្រាគួរត្រូវបានទទួលយកធ្វើជាភស្តុតាងសាធារណៈ។

*(៣) កំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877)*

26. លោក Robert Lemkin (2-TCW-877) ត្រូវបានស្តាប់ចម្លើយកាលពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៦ ដោយចៅក្រមតំណាងអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងពេលធ្វើការស៊ើបសួរបន្ថែមទាក់ទងនឹងខ្សែភាពយន្ត "សត្រូវប្រជាជន"[86]។ មេធាវីការពារក្តីសូមលើកឡើងថា កំណត់ហេតុស្តាបចម្លើយរបស់ Robert Lemkin (2-TCW-877) គួរត្រូវបានទទួលយកធ្វើជាភស្តុតាង ដោយសារតែវាផ្តល់នូវព័ត៌មានអំពីប្រវត្តិរបស់ Robert Lemkin (2-TCW-877)[87] ចំណេះដឹងរបស់គាត់ស្តីពីកម្ពុជាជាទូទៅ និងជាពិសេសអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ[88] និងអំពីវិធីសាស្ត្រដែលត្រូវបានអនុវត្តសម្រាប់ការសម្ភាសន៍សាក្សីទាំងបួនរូប[89] ហើយមេធាវីការពារក្តីអាចសួរដេញដោល [redacted] (2-TCW-829) ដោយប្រើប្រាស់ឯកសារនេះ។

27. ការរៀបរាប់អំពីវិធីសាស្ត្រដែលអនុវត្តដោយ Robert Lemkin (2-TCW-877) មានសារៈសំខាន់សម្រាប់ឱ្យអង្គជំនុំជម្រះ និងភាគី អាចវាយតម្លៃភាពត្រឹមត្រូវនៃប្រតិចារឹករបស់ការសម្ភាសន៍ដែលបានស្នើសុំឱ្យទទួលយក។ ត្រង់ចំណុចនេះ វាហាក់ដូចជាថា Robert Lemkin (2-TCW-877) និងថេត សម្បត្តិ (2-TCW-885) បានជ្រើសរើសវិធីសាស្ត្រដែលល្អ ដោយមានការការពារមួយចំនួន ដើម្បីធានាពីភាពអាចជឿជាក់បាននៃសក្ខីកម្មនីមួយៗ។

ឆ២០៖ ពួកគេត្រូវបានសម្ភាសន៍ជាច្រើនដង គឺជាងដប់ដង។ ព័ត៌មានរបស់ពួកគេត្រូវបានសួរផ្ទុញជាច្រើនដង ហើយមានការព្យាយាមដើម្បីស្រាវជ្រាវបែប triangulate ឬ ដើម្បីគាំទ្រដល់

[86] ឯកសារ **F2/4/3/1**, កំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877)។

[87] ឯកសារ **F2/4/3/1**, កំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877), ERN 01097180។

[88] ឯកសារ **F2/4/3/1**, កំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877), ERN 01097181។

[89] ឯកសារ **F2/4/3/1**, កំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877), ERN 01097183-86។

ព័ត៌មាន ដោយការសួរអ្នកដទៃអំពីព័ត៌មាន ដែលមនុស្សម្នាក់បានផ្តល់ឱ្យ។ យើងនឹងសួរអ្នកដទៃថា តើពួកគេដឹងអំពីចំណុចនេះទេ។ ប្រសិនបើព័ត៌មាននោះហាក់ដូចជាស៊ីសង្វាក់គ្នា នោះព័ត៌មាននេះនឹងនាំយើងទៅរកមនុស្សដែលសមស្រប សម្រាប់ដាក់បញ្ចូលទៅក្នុងខ្សែភាពយន្ត[90]។

*(៤) អត្ថបទសារព័ត៌មាន Cambodia Daily Weekend ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦*

28. នៅថ្ងៃសៅ ទី១៨ ខែមិថុនា ឆ្នាំ២០១៦ សារព័ត៌មាន Cambodia Daily បានចេញលេខចុងសប្តាហ៍ពិសេសមួយ។ សារព័ត៌មានលេខនេះមានអត្ថបទដែលមានចំណងជើងថា 'Factions or Fictions?' ដែលសរសេរដោយ George Wright ដែលរៀបរាប់ពីសំណុំរឿង នួន ជា និងមានសម្រង់ពីអត្ថបទសិក្សាស្រាវជ្រាវ[91] ព្រមទាំងការសម្ភាសន៍ជាមួយអ្នកសិក្សាជាន់ខ្ពស់ និងអ្នកស្រាវជ្រាវ ដែលក្នុងនោះមាន Robert Lemkin (2-TCW-877) និង [redacted] (2-TCE-87) ផងដែរ។ ពួកគាត់បានបញ្ជាក់ថាបានរកឃើញថា ក្រុមផ្តាច់ខ្លួនផ្ទៃក្នុងពិតជាបានរៀបចំផែនការបះបោលប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយមជ្ឈិមបក្សនៅពេលនោះ គិតដោយត្រឹមត្រូវថាបានរងការគម្រាមកំហែងដោយមេដឹកនាំភូមិភាគ រួមទាំង រស់ ញឹម និងសោ ភឹម ផង[92]។ ហេតុដូច្នេះ មេធាវីការពារក្តីសូមលើកឡើងថា អត្ថបទនេះពិតជាពាក់ព័ន្ធយ៉ាងខ្លាំងជាមួយនឹងការរៀបចំរឿងក្តីរបស់ នួន ជា ហើយគួរត្រូវបានទទួលយកធ្វើជាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២។

29. Robert Lemkin (2-TCW-877) បានប្រាប់ Georges Wright ថា៖

> នៅក្នុងរយៈពេលប៉ុន្មានខែក្រោយពេលខ្មែរក្រហម គឺ ប៉ុល ពត នួន ជា និងអ្នកផ្សេងទៀតឡើងគ្រប់គ្រងអំណាច មេដឹកនាំជាន់ខ្ពស់ក្នុងបក្សកុម្មុយនីស្តកម្ពុជា បានធ្វើផែនការផ្តាច់ខ្លួនដើម្បីបំបែកកងទ័ព និងរដ្ឋបាលគាំទ្រ ហើយពួកគេព្យាយាមស្វែងរកវិធីដើម្បីសម្រេច

[90] ឯកសារ **F2/4/3/1**, កំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-877), ERN 01097184។

[91] សូមមើល 'Cambodia Daily Weekend', ថ្ងៃទី១៨ ១៩ ខែមិថុនា ឆ្នាំ២០១៦ (ឧបសម្ព័ន្ធ ២), ទំព័រ ៥ ដកស្រង់អត្ថបទរបស់ Anthony Paul នៅក្នុងទស្សនាវដ្តី Asiaweek ថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៧៩។ https://www.cambodiadaily.com/weekend1/factions-or-fiction-114272/។

[92] 'Cambodia Daily Weekend', ថ្ងៃទី១៨-១៩ ខែមិថុនា ឆ្នាំ២០១៦ (ឧបសម្ព័ន្ធ ២), ទំព័រ ៥ ដល់៧, https://www.cambodiadaily.com/weekend1/factions-or-fiction-114272/។

គោលដៅនោះ។ នេះគឺពិតជាសង្គ្រាមស៊ីវិលមួយប្រភេទ ដែលបានបន្តនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែ វាជាសង្គ្រាមស៊ីវិលសម្ងាត់ដោយសារតែលក្ខណៈនៃរដ្ឋផ្ដាច់ការដែលពួកគេបានបង្កើតឡើង ដោយបិទព្រំដែនមិនទំនាក់ទំនងជាមួយពិភពលោក ទើបពិភពលោកមិនបានដឹងឲ្យប្រាកដថា មានអ្វីបានកើតឡើងពិតប្រាកដ (...) ដូចជា រស់ ញឹម ដែលមានស្វ័យភាពច្រើននៅក្នុងតំបន់របស់ពួកគេ[93]។

30. [redacted] (2-TCE-87) ក៏បានផ្ដល់សម្ភាសន៍សម្រាប់អត្ថបទនេះដែរ ដោយបញ្ជាក់ថា មុនពេល អៀង សារីស្លាប់ [redacted]៖

> ស្ទូម្បី ប៉ុល ពត និង នួន ជា នៅពេលដែលពួកគេនៅក្នុងភូមិភាគរបស់ សោ ភឹម, ភូមិភាគបូព៌ា ក៏ពួកគេខ្លាចតាភឹមដែរ។ (...) ខ្ញុំធ្លាប់ទៅជាមួយពួកគេម្ដង ហើយខ្ញុំដឹង និងបានឃើញបែបនេះ។ គឺថា ប៉ុល ពត ផ្ទាល់ក៏មិនហ៊ានទៅក្រោមដែរ គឺគាត់ខ្លាចតាភឹម (...) ដូចនេះនៅក្នុងភូមិភាគនេះ ប្រសិនបើ សោ ភឹម ចង់សម្លាប់ ឬចង់ធ្វើអ្វី ក៏គាត់មិនចាំបាច់ត្រូវសួរថ្នាក់លើដែរ។ អង្គការគឺបែបនេះ ភូមិភាគនីមួយៗឯករាជ្យ គឺឯករាជ្យសឹងតែថា ប្រសិនបើអ្នកចង់សម្លាប់ អ្នកអាចធ្វើបានតាមចិត្ត[94]។

## ខ. ឯកសារដែលបានស្នើសុំឱ្យទទួលយក មិនអាចរកបាននៅមុនពេលចាប់ផ្ដើមសវនាការឡើយ

31. អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា សវនាការនៅក្នុងសំណុំរឿង ០០២/០២ ចាប់ផ្ដើមនៅក្នុងខែ មិថុនា ឆ្នាំ ២០១១[95]។ មេធាវីការពារក្ដីបានទទួលកំណត់ត្រារបស់ Robert Lemkin (2-TCW-877)នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៥ ហើយបានទទួលប្រតិចារឹកនៅថ្ងៃទី២ ខែតុលា ឆ្នាំ

---

[93] 'Cambodia Daily Weekend', ថ្ងៃទី១៨-១៩ ខែមិថុនា ឆ្នាំ២០១៦ (ឧបសម្ព័ន្ធ ២), ទំព័រ ៥ ដល់៦, https://www.cambodiadaily.com/weekend1/factions-or-fiction-114272/។

[94] 'Cambodia Daily Weekend', ថ្ងៃទី១៨-១៩ ខែមិថុនា ឆ្នាំ២០១៦ (ឧបសម្ព័ន្ធ ២), ទំព័រ ៦ ដល់៧, https://www.cambodiadaily.com/weekend1/factions-or-fiction-114272/។

[95] ឯកសារ **E307/1**, "សេចក្ដីសម្រេចលើសំណើរួមរបស់ភាគី សុំការបញ្ជាក់បំភ្លឺទាក់ទង ការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (E307) និងការជូនដំណឹងរបស់មេធាវីការពារក្ដី នួន ជា ពីការមិនដាក់បញ្ជីភស្តុតាងដែលកែប្រែថ្មី (E305/3)", ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ , កថាខណ្ឌ ២។ ឯកសារ **E307/1/2**, "សេចក្ដីសម្រេចលើសំណើរួមសុំឲ្យ សម្រេចសាជាថ្មីឡើងវិញ លើការអនុវត្តវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង", ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៤, កថាខណ្ឌ ៦។

២០១៥ និងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥។ អត្ថបទរបស់សារព័ត៌មាន Cambodia Daily Weekend ត្រូវបានចេញផ្សាយនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦។ ហេតុដូច្នេះ មេធាវីការពារក្តីមិនអាចរកបានសម្ភារៈដែលបានស្នើសុំ នៅមុនពេលបើកសវនាការឡើយ។ ដូច្នេះ សម្ភារៈនេះអាចសមស្របសម្រាប់ទទួលយកធ្វើជាភស្តុតាងអនុលោមតាមវិធាន ៨៧(៤)។

32. លើសពីនេះទៀត មេធាវីការពារក្តីបានកត់សម្គាល់ថា ខ្លួនបានសាកសួរមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះតុលាការកំពូល អំពីស្ថានភាពនៃប្រតិចារឹករបស់ Robert Lemkin (2-TCW-877) បន្ទាប់អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំចូលពិនិត្យមើលសម្ភារៈនេះ។ នៅថ្ងៃទី១១ ខែមេសា ឆ្នាំ ២០១៦ ក្រឡាបញ្ជីនៃអង្គជំនុំជម្រះតុលាការកំពូលបានចេញអនុស្សរណៈអន្តរការិយាល័យមួយ ជូនដំណឹងដល់ភាគីថា សិទ្ធិចូលពិនិត្យមើលភស្តុតាង ដែល Robert Lemkin (2-TCW-877) បានផ្តល់មកអង្គជំនុំជម្រះតុលាការកំពូល ត្រូវបានអនុញ្ញាតដល់អង្គជំនុំជម្រះសាលាដំបូង[96]។ ហេតុដូច្នេះ មេធាវីការពារក្តីសន្និដ្ឋានជាបឋមថា អង្គជំនុំជម្រះសាលាដំបូងនឹងស្នើសុំសារណាពីភាគីនានាអំពីបញ្ហាថាតើសម្ភារៈនេះគួរត្រូវបានទទួលយកធ្វើជាភស្តុតាងដែរឬយ៉ាងណា នៅក្នុងសំណុំរឿង ០០២/០២ មុនពេល [redacted] (2-TCW-829) បង្ហាញខ្លួន។ យោងតាមបញ្ជីសាក្សីបឋមដែលអង្គជំនុំជម្រះសាលាដំបូងបានផ្តល់ឱ្យសម្រាប់វគ្គស្តីពី "ការបោសសម្អាតផ្ទៃក្នុង" [redacted] (2-TCW-829) គ្រោងនឹងមកផ្តល់សក្ខីកម្មនៅសប្តាហ៍ខាងមុខ[97]។ ហេតុដូច្នេះ មេធាវីការពារក្តីសូមលើកឡើងថា សំណើពេលនេះគឺមិនយឺតយ៉ាវឡើយ។

## V. សំណូមពរ

33. សម្រាប់សំអាងហេតុដូចបានបញ្ជាក់ខាងលើ មេធាវីការពារក្តីសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង មេត្តាទទួលយកឯកសារខាងក្រោមធ្វើជាភស្តុតាងក្នុងសំណុំរឿង ០០២/០២ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង មុនពេលសាក្សី [redacted] **(2-TCW-829)** មកបង្ហាញខ្លួន៖

(i) កំណត់ត្រា, ប្រតិចារឹក និងកំណត់ហេតុស្តាប់ចម្លើយ Robert Lemkin (2-TCW-

---

[96] ឯកសារ **E375/2/1**, "អនុស្សរណៈអន្តរការិយាល័យ", ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦។

[97] សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់ ផ្ញើរជូនភាគី, ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦។

877) និង

(ii) អត្ថបទរបស់សារព័ត៌មាន Cambodia Daily Weekend ដែលមានចំណងជើងថា 'Factions or Fictions?' ចេញផ្សាយថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០១៦។

សហមេធាវីការពារក្តី នួន ជា

សុន អរុណ                Victor KOPPE